# រោគ Hepatitis C – ហេតុការណ៍

## តើរោគ hepatitis ជាអ្វីទៅ?

*Hepatitis* គឺជាពាក្យទូទៅដែលប្រើដើម្បីពណ៌នាអំពីការរលាកថ្លើម។ សុរា ជាតិគីមី និងថ្នាំអាចបណ្ដាលឲ្យមានការរលាកថ្លើម។ រោគនេះអាចបណ្ដាលដោយការឆ្លងវីរុសផងដែរ។ រោគ hepatitis មានច្រើនប្រភេទ រួមមានប្រភេទ A, B, C, D, E, F និង G ។

វីរុសទាំងនេះប្រហែលជាបង្កើតអាការរោគស្រដៀងគ្នា ប៉ុន្តែ ឆ្លងខុសៗគ្នា ដូច្នេះការការពារនិងការគ្រប់គ្រងគឺមានសភាពផ្សេងគ្នា។ ចំពោះវេជ្ជសាស្ត្រវិញ រោគទាំងនេះត្រូវបានចាត់ទុកថាជាជម្ងឺខុសគ្នា។

ខិត្តប័ណ្ណនេះ គឺអំពីរោគ hepatitis C តែប៉ុណ្ណោះ។

## តើអ្វីជាអាការរោគរបស់វា?

នៅក្នុងករណីជាច្រើន អ្នកដែលមានវីរុស hepatitis C ប្រហែលជាមិនឈឺឡើយ ចំណែកអ្នកដទៃទៀតប្រហែលជាជួបប្រទះនឹងជម្ងឺ "ដូចគ្រុនផ្ដាសាយ" តិចតួច ដែលមិនត្រូវការការព្យាបាល។

ទោះជាយ៉ាងណាក្ដីក៏នៅពេលដែលកើតមាន hepatitis C ជាដំបូងឡើង ទឹកនោមអ្នកខ្លះប្រហែលជាមានពណ៌ក្រម៉ៅ ហើយផ្នែកពណ៌សនៃភ្នែកហើយនិងស្បែករបស់គេ ប្រហែលជាឡើងពណ៌លឿង(ខាន់លឿង)។ អាការរោគ hepatitis ប្រហែលជាបាត់ទៅវិញនៅក្នុងពេលពីរបីអាទិត្យ ប៉ុន្តែនេះមិនចាំបាច់មានន័យថា រោគនោះបានបាត់រូបរាងផងដែរនោះទេ។ បើសិនជាអ្នកមានអាការរោគ hepatitis អ្នកគប្បីទៅជួបវេជ្ជបណ្ឌិតអ្នក។

ការរលាកថ្លើមអាចកំណត់ដោយការធ្វើតេស្តឈាម ដើម្បីវាស់មើលអង់ហ្ស៊ីមពីររបស់ថ្លើម (ALT និង AST) ។ កំពស់នៃអង់ហ្ស៊ីមទាំងនេះ ចង្អុលបង្ហាញអំពីការខូចខាតថ្លើមជាបន្តទៅទៀត។

នៅពេលដែលការរលាកថ្លើមនៅមាននៅក្នុងរយៈពេលយូរជាងប្រាំមួយខែ ជម្ងឺនេះត្រូវបានហៅថា hepatitis C រ៉ាំរ៉ៃ។

អាការរោគ hepatitis C រ៉ាំរ៉ៃ ប្រហែលជារួមមាន:

- ការអស់កម្លាំងបន្តិចបន្តួចរហូតដល់ខ្លាំងមែនទែន។
- ពុំឃ្លានចំណីអាហារ។
- ដំណើរចង់ក្អួត និងក្អួត។
- ឈឺពោះផ្នែកខាងលើ (នៅក្រោមឆ្អឹងជំនី)។
- គ្រុន។
- ឈឺសន្លាក់។

## តើរោគ hepatitis C មានគ្រោះថ្នាក់ឬ?

ជាង 70 ភាគរយនៃអ្នកដែលកើតរោគនេះ ប្រហែលជាបន្តមានវីរុសនេះនៅក្នុងឈាមរបស់គេ ហើយក្លាយជាអ្នកពាំនាំរោគនេះក្នុងរយៈពេលយូរឬរ៉ាំរ៉ៃ។ គេមានជំនឿថា អ្នកពាំនាំរោគរ៉ាំរ៉ៃនេះយ៉ាងតិច 20 ភាគរយ នឹងកើតទៅជារោគ cirrhosis ដែលបង្កឲ្យមានស្លាមនៅនឹងថ្លើម។ ដំណើរការនេះប្រហែលជាត្រូវការពេល 20 ឆ្នាំ ដើម្បីកើតឡើង។ នៅពេលប៉ុន្មានឆ្នាំក្រោយមក អ្នកជម្ងឺមួយភាគជាក់លាក់ដែលមានរោគ cirrhosis ប្រហែលជាកើតទៅជារោគមហារីកថ្លើម។

គេមានជំនឿថា អ្នកពាំនាំរោគhepatitis C ប្រហែលជានៅតែមានរោគនេះពេញមួយជីវិតរបស់គេ ហេតុដូច្នេះប្រហែលជាមានសមត្ថភាពដើម្បីចម្លងរោគនេះទៅកាន់ជនដទៃនៅគ្រប់ពេលវេលា។

## តើរោគ hepatitis C ឆ្លងតាមរបៀបណាទៅ?

Hepatitis C គឺជារោគឆ្លងតាមឈាម ដែលមានន័យថា ការឆ្លងរោគកើតឡើងតាមការទាក់ទងចេញពីឈាមទៅកាន់ឈាម។ វីរុស hepatitis C មានវត្តមាននៅក្នុងឈាមនៃអ្នកដែលមានរោគ hepatitis C ។ ការចម្លងវីរុសនេះ ជាញឹកញយបំផុតគឺកើតឡើងនៅពេលដែលឈាមមានរោគ ចូលទៅក្នុងដំណើរឈាមរត់នៃជនម្នាក់ទៀត តាមរយៈស្បែកដាច់រហែក ឬក៏ភ្នាសសំណើម (ដូចជាស្បែកសើមនៅក្នុងច្រមុះ មាត់ បំពង់កជាដើម)។

ភាគច្រើននៃប្រជាជនក្នុងប្រទេសអូស្ត្រាលីដែលមាន hepatitis C ឆ្លងរោគនេះដោយសារការប្រើសំភារៈចាក់ថ្នាំរួមគ្នា ដូចជាម្ជុលនិងសឺរាំង ស្លាបព្រា ប្រដាប់ដុសលាង និងទឹក។ ការប្រើឧបករណ៍ទាំងឡាយ ដូចជាម្ជុលសម្រាប់សាក់ដែលមិនមានរម្ងាប់មេរោគមុនចាក់ទៅក្នុងស្បែក អាចចម្លងវីរុសនេះផងដែរ។ ការប្រើកាំបិតកោរ ឬច្រាសដុសធ្មេញរួមគ្នា ដែលជារបស់អ្នកមានរោគ hepatitis C ប្រហែលជាធ្វើឲ្យមានការឆ្លងរោគនេះផងដែរ។

វីរុសនេះក៏អាចឆ្លងទៅតាមវិធីដូចតទៅនេះ :

- **បុគ្គលិកថែទាំសុខភាព**
  ការឲ្យឈាមមានរោគប៉ះពាល់ទៅលើកន្លែងស្បែកមុតដាច់និងកកោសដាច់ឬក៏មានរបួសដោយសារឧបករណ៍មានមេរោគនៅក្នុងចំណោមបុគ្គលិកថែទាំសុខភាព អាចបណ្ដាលឲ្យឆ្លងរោគ។
- **ពីម្ដាយទៅកាន់ទារក**
  រោគ hepatitis C ប្រហែលជាឆ្លងពីម្ដាយទៅទារក ប៉ុន្តែការឆ្លងនេះទំនងជាមានតិចជាងការឆ្លងរោគ hepatitis B ជាទូទៅជាខ្លាំង។ លទ្ធភាពគ្រោះថ្នាក់នៃការឆ្លងវីរុសតាមទឹកដោះ ត្រូវបានគិតថាមានតិចតួចណាស់។
- **ការរួមរ័ក្ស**
  លទ្ធភាពគ្រោះថ្នាក់ក្នុងការចម្លងរោគ hepatitis C ក្នុងកម្លុងការរួមរ័ក្សរវាងមនុស្សភេទផ្ទុយគ្នានិងភេទដូចគ្នា គឺមានតិចតួចណាស់ ជាពិសេសបើសិនជាដៃគូម្នាក់មានរោគ hepatitis C ខ្លាំងក្លានោះ។
- **អ្នកធ្វើអំណោយឈាម**
  អ្នកធ្វើអំណោយឈាម ពុំមានលទ្ធភាពមានគ្រោះថ្នាក់ឆ្លងរោគនេះឡើយ ហើយគ្រាសព្វថ្ងៃនេះលទ្ធភាពមានគ្រោះថ្នាក់ចំពោះអ្នកទទួលការចាក់បញ្ចូលឈាមវិញ គឺមានតិចតួចណាស់ ដោយសារថា ចាប់ពីឆ្នាំ 1990 មក ការធ្វើអំណោយឈាមទាំងអស់ ត្រូវបានឆែករកមើលរោគ hepatitis C ។

## តើនរណាទៅដែលមានលទ្ធភាពមានគ្រោះថ្នាក់?

អ្នកដែលនៅក្នុងក្រុមដូចតទៅនេះ មានកំណើននៃលទ្ធភាពមានគ្រោះថ្នាក់ ក្នុងការឆ្លងរោគ hepatitis C ។

- អ្នកប្រើថ្នាំដោយការចាក់ម្ជុល ដែលប្រើម្ជុលនិងសឺរាំងរួមគ្នា។

- អ្នកឆ្លងកាត់ទំរង់ការចាក់ចូលតាមស្បែក ដូចជាសាក់ និងចោះរាងកាយ ដោយសំភារៈមិនមានរម្ងាប់មេរោគ។
- អ្នកទទួលការចាក់បញ្ចូលឈាមមុនខែកុម្ភៈ ឆ្នាំ 1990 ។
- បុគ្គលិកថែទាំសុខភាពដោយវិជ្ជាជីវៈរបស់គេបានធ្វើឲ្យគេប៉ះពាល់ឈាម។
- អ្នកជម្ងឺតំរងទឹកម៉ូត្រដែលត្រូវការការបញ្ចេញជាតិសំណល់ចេញពីឈាម និងអ្នកដែលមានបញ្ហាដោយសារឈាមមិនកក។

ចំនួនប្រមាណជា 25 ភាគរយនៃអ្នកដែលមានរោគ hepatitis C មិនទំនងជាឋិតនៅក្នុងក្រុមខាងលើនេះឡើយ។

## តើខ្ញុំចៀសវាងមិនឆ្លងរោគនេះតាមរបៀបណា?

- ចំពោះអ្នកដែលចាក់ថ្នាំ :
  - លាងសំអាតដៃអ្នកជាដរាប មុនពេលនិងក្រោយពេលចាក់។
  - កុំប្រើរួមគ្នានូវម្ជុល សឺរាំង និងសំភារៈដទៃទៀតទាល់តែសោះ ដូចជាស្លាបព្រា ប្រដាប់ដុសលាង ទឹកជាដើម។ល។ ប្រើម្ជុល និងសឺរាំងស្អាតល្អជាដរាប។ សំភារៈទាំងនេះមាននៅឯឱសថស្ថានខ្លះនិងកន្លែងប្តូរម្ជុលនិងសឺរាំង។ ដើម្បីទទួលពត៌មានបន្ថែមអំពីទីកន្លែងទទួលម្ជុលនិងសឺរាំងស្អាតល្អ ឬបើចាំបាច់អំពីរបៀបសំអាតសំភារៈទាំងនេះ សូមទាក់ទង DIRECTLINE តាមលេខ (03) 9416 1818 ឬ 1800 136 385 ។
- ចូរកុំប្រើសំភារៈផ្ទាល់ខ្លួនរួមគ្នា ដូចជាច្រាសដុសធ្មេញ កាំបិតកោរ ប្រដាប់ដុសខាត់ឬកាត់ក្រចក ដោយសារថា សំភារៈទាំងនេះអាចទម្លុះស្បែក ហើយប្រឡាក់ដោយឈាម។
- ចំពោះអ្នកធ្វើឬអ្នកទទួលការចោះរន្ធត្រចៀក ការសាក់ អគ្គិសនីវិភាគឬម្ជុលវិទ្យាសាស្ត្រវិញ ត្រូវធ្វើឲ្យប្រាកដជាដរាបថា សំភារៈណាមួយដែលចាក់ទម្លុះស្បែក ត្រូវតែរម្ងាប់មេរោគ បន្ទាប់ពីប្រើហើយ។
- បុគ្គលិកថែទាំសុខភាពគប្បីគោរពទៅតាមសេចក្តីណែនាំជាទូទៅលើការទប់ទល់ការឆ្លងរោគ។
- ប្រតិបត្តិ"ការរួមរ័ក្សមានសុវត្ថិភាព"។ ចំពោះអ្នកសកម្មខាងការរួមរ័ក្សវិញ ការប្រើស្រោមការពារដោយត្រឹមត្រូវនិងមិនផ្លាស់ប្តូរសំរាប់ការរួមភេទតាមយោនីនិងដោយមាត់ជាមួយបុរសនិងស្ត្រីនឹងកាត់បន្ថយលទ្ធភាពមានគ្រោះថ្នាក់លើការឆ្លងរោគ។ អ្នកដែលមានទំនាក់ទំនងមានស្ថិរភាពរយៈពេលយូរ ត្រូវការគិតគូរនិងពិភាក្សាលើការប្រើស្រោមការពារជាមួយវេជ្ជបណ្ឌិតរបស់គេ។

នៅគ្រាសព្វថ្ងៃនេះ គេមិនមានថ្នាំចាក់ដើម្បីការពារមិនឲ្យឆ្លងរោគ hepatitis C ឡើយ។

## តើខ្ញុំគួរធ្វើអ្វីបើខ្ញុំមានរោគ hepatitis C រួចទៅហើយនោះ?

- ចៀសវាងកុំសេពសុរា (កុំឲ្យលើសពីខ្នាតកម្រិត "standard drink" បួនប្រាំដងសំរាប់បុរស និងបីបួនដងសម្រាប់ស្ត្រី ក្នុងមួយអាទិត្យ) ពីព្រោះសុរាបង្កើនល្បឿនការកើតទៅជា cirrhosis ។
- ពិគ្រោះយោបល់វេជ្ជបណ្ឌិតអ្នក ដែលនឹងតាមពិនិត្យស្ថានភាពអ្នក ហើយបើចាំបាច់ នឹងបញ្ជូនអ្នកទៅជួបអ្នកឯកទេស។
- រក្សាការបរិភោគចំណីអាហារមានគ្រឿងធ្វើឲ្យធំធាត់ ដែលមានលំនឹងយ៉ាងល្អ និងមានជាតិខ្លាញ់តិច។
- សំរាកនៅពេលអ្នកមានអារម្មណ៍មិនស្រួលខ្លួន។

## តើខ្ញុំគួរធ្វើអ្វីដើម្បីបញ្ឈប់ការរីកសាយភាយនៃ hepatitis C?

បើអ្នកមានវីរុស hepatitis C អ្នកគួរប្រកាន់ការប្រុងប្រយ័ត្នជាមុនដូចតទៅនេះ ដើម្បីការពារកុំឲ្យរាលដាល :

- ពិភាក្សាស្ថានភាពអ្នកជាមួយអ្នកផ្តល់ការថែទាំសុខភាពអ្នក នៅពេលឆ្លងកាត់ទំរង់ការណាមួយដើម្បីព្យាបាលឬធ្វើធ្មេញ។
- ជូតការកំពប់ហូរឈាមណាមួយចេញឲ្យបានហ្មត់ចត់ ដោយប្រើស្រោមដៃជាមួយថ្នាំធ្វើឲ្យសដែលប្រើក្នុងផ្ទះ និងកន្សែងក្រដាសដែលអាចបោះចោលបាន។
- ប្រើក្រណាត់រុំដំបៅឬបន្ទះ bandaid ដើម្បីរុំបិទគ្របកន្លែងមុតឬរបួសឲ្យបានពេញលេញ។
- ដាក់ក្រដាសទន់ដែលប្រឡាក់ឈាម កន្សែងអនាម័យ ឬក្រណាត់រុំដំបៅឯទៀតដែលប្រឡាក់ឈាម ទៅក្នុងស្បោងផ្លាស្ទិក មុនពេលបោះចោល។
- ប្រតិបត្តិការរួមរ័ក្សមានសុវត្ថិភាព ក្នុងកម្លុងដំណាក់កាលខ្លាំង។

អ្នកមិនគប្បី :

- ធ្វើអំណោយឈាម ឬសរីរាង្គដទៃទៀតនៃរាងកាយ។
- ប្រើសំភារៈចាក់រួមគ្នា។
- ប្រើសំភារៈផ្ទាល់ខ្លួនរួមគ្នា ដូចជាច្រាសដុសធ្មេញ ឬកាំបិតកោរ។

## តើមានវិធីព្យាបាលរោគ hepatitis C រាំរ៉ៃឬទេ?

ការព្យាបាលដោយប្រើថ្នាំប្រឆាំងវីរុសត្រូវបានប្រើដើម្បីបន្ថយការរលាកថ្លើម។ វាមានឥទ្ធិពលបន្ទាប់បន្សំធំៗខ្លះ ហើយលទ្ធផលនៃការសិក្សារបស់អូស្ត្រាលីនិងបរទេសផ្តល់មតិថា មនុស្សម្នាក់ក្នុងចំណោមប្រាំនាក់ ប្រហែលជាទទួលប្រយោជន៍ក្នុងរយៈពេលយូរ។ អ្នកគួរពិភាក្សានឹងវេជ្ជបណ្ឌិតអ្នក អំពីជំរើសនៃការព្យាបាលទាំងឡាយ។

## តើមានការធ្វើតេស្តសំរាប់រោគ hepatitis C ឬ?

ការធ្វើតេស្តឈាមសំរាប់ hepatitis C មាននៅឆ្នាំ 1990 ។ វាប្រហែលជាត្រូវការពេលពីរឬបីខែចាប់ពីពេលឆ្លងរោគនេះ មុនពេលការធ្វើតេស្តឈាមអាចតាមរកមើលភស្តុតាងនៃការឆ្លងរោគ (គឺថា មានវត្តមាននៃអង្គបដិបក្ខនៅក្នុងឈាម)។ តេស្តនេះអាចបង្ហាញថា អ្នកកើតមានរោគនេះនៅពេលណាមួយកាលពីពេលកន្លងមកតែប៉ុណ្ណោះ ប៉ុន្តែមិនអាចកំណត់ថាតើអ្នកកើតមានរោគនេះក្លាយទៅជា អ្នកពាំនាំរោគឡើយ។

មន្ទីរពិសោធន៍ឯកទេសអាចធ្វើតេស្តដែលប្រហែលជាជួយរកមើលថាតើវីរុសនេះនៅតែមានវត្តមាននៅក្នុងឈាមឬថ្លើមនៃជនម្នាក់បាន ប៉ុន្តែតេស្តប្រភេទនេះមិនធ្វើទៅជាប្រក្រតីឡើយ ហើយថ្លៃទៀតផង។

## ពត៌មានបន្ថែម

ដើម្បីទទួលពត៌មានបន្ថែម សូមទាក់ទង :

Hepatitis C Helpline
ទូរស័ព្ទលេខ (03) 9349 1111
អ្នកនៅជនបទប្រើលេខ 1800 800 241
ឬ
Hepatitis C Support Line
Hepatitis C Council
Level 9
Carlow House
289 Flinders Lane
Melbourne 3000
ទូរស័ព្ទលេខ (03) 9639 3200
អ្នកនៅជនបទប្រើលេខ 1800 703 003

បោះផ្សាយដោយ Infectious Disease Unit, Public Health Branch, Victorian Government Department of Human Services.

ខិត្តប័ណ្ណនេះផ្អែកទៅលើពត៌មានចុងក្រោយដែលមាននៅត្រឹមខែមេសា 1998 ។

រៀបចំនិងផលិតដោយ Human Services Promotion Unit